00164892

E11/45



# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ប.ជ |
| បញ្ជូនទៅ: | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទនៃការបញ្ជូន | ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨ |
| ភាគីបញ្ជូន: | នួន ជា<br>អៀង សារី<br>អៀង ធិរិទ្ធ និង<br>ខៀវ សំផន |
| ភាសាដើម: | ខ្មែរ អង់គ្លេស និង បារាំង |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25/02/2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22/02/2008
ម៉ោង (Time/Heure): 15h15 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

## សារណារួមគ្នាស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

<u>បញ្ជូនដោយ៖</u>

**សហមេធាវីការពារលោក នួន ជា**

លោកមេធាវី សុន អរុណ

លោកមេធាវី Michiel PESTMAN

លោកមេធាវី Victor KOPPE

**សហមេធាវីការពារលោក អៀង សារី**

លោកមេធាវី អាង ឧត្តម

លោកមេធាវី Michael KARNAVAS

<u>អ្នកទទួលឯកសារ:</u>

**ចៅក្រមនៃអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ធុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

**សហមេធាវីការពារអ្នកស្រី អៀង ធិរីទ្ធ**

លោកមេធាវី ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

**សហមេធាវីការពារលោក ខៀវ សំផន**

លោកមេធាវី សាយ បូរី

លោកមេធាវី Jacques VERGES

**មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកមេធាវី ហុង គីមសួន

លោកមេធាវី ឡោ ជុនធី

លោកមេធាវី នី ចាន់ឌី

## I. សេចក្ដីផ្ដើម

1. មេធាវីការពារក្ដីរបស់ជនត្រូវចោទ **នួន ជា, អៀង សារី, អៀង ធិរិទ្ធ** និង **ខៀវ សំផន**(ហៅថា“មេធាវីការពារក្ដី”រួមគ្នា) សុំដាក់សារណារួមគ្នា និង សារណាជាច្រើន អនុលោមតាម"សេចក្ដីជូនដំណឹងជាសាធារណស្ដីពីការដាក់សារណាអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងរឿងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងការអញ្ជើញអ្នកដែលមិនមែនភាគី (ហៅថា“សេចក្ដីជូនដំណឹង”) របស់អង្គបុរេជំនុំជម្រះ (ហៅថា“អ.ប.ជ”)។[1]

2. មូលហេតុដូចបញ្ជាក់ខាងក្រោម មេធាវីការពារជំទាស់នឹងការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ។ ការចូលរួមបែបនេះមិនត្រូវបានអនុញ្ញាតដោយច្បាប់កម្ពុជាទេ ហើយចាប់អនុវត្តន៍គោលការណ៍អន្តរជាតិ ដោយមិនបានបង្ហាញផលប្រយោជន៍ដែលកើតចេញពីលទ្ធផលនៃដំណើរការនីតិវិធី ។

3. អនុលោមទៅតាមខ្លឹមសារនៃសេចក្ដីជូនដំណឹង សារណាដ៏ប្រញាប់ប្រញាល់នេះកំណត់ត្រឹមតែបញ្ហាការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្នតែប៉ុណ្ណោះ ។

## II. អង្គហេតុពាក់ព័ន្ធ

4. មកដល់ពេលនេះ មានបុគ្គលប្រាំបី(៨)នាក់ បានដាក់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីស្របតាមវិធាន ២៣ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (ហៅថា”វិធានផ្ទៃក្នុង”)[2] ។ ក្រឡាបញ្ជីរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត(ហៅថា “ក.ស.ច.ស”) បានទទួលស្គាល់ជាបណ្ដោះអាសន្ននូវការសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់បុគ្គលបួន(៤)នាក់ “មុនមានសេចក្ដីពីសហចៅក្រមស៊ើបអង្កេត"[3]។បុគ្គលទាំងបួននេះ (ហៅថា"ដើមបណ្ដឹងរដ្ឋប្បវេណី”រួមគ្នា) មិនបានបញ្ចូលនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យទៅស៊ើបសួរ ឬនៅលើឯកសារដទៃទៀតថាជាសាក្សីនោះទេ ។

---

[1] ឯកសារលេខ C-11/36, ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ ។ ភាគីមានសិទ្ធិដាក់សារណាឆ្លើយតបទៅនឹងសារណារបស់ការិយាល័យព្រះរាជអាជ្ញា និង/ឬបុគ្គលមិនមែនជាភាគីរឿងក្ដី ។

[2] សូមមើលឯកសារលេខ [D-22/1, D-22/2, D-22/3, D-22/4, D-22/5, D-22/6, D-22/7 និង D-22/8]

[3] សូមមើលឯកសារលេខ [D-22/1/1, D-22/2/2, D-22/6/2, និង D-22/7/2] ។ ទោះបីអត្តសញ្ញាណរបស់ពួកគេបានបង្ហាញដល់មេធាវីការពារក្ដីដោយ ក.ស.ច.ស ក៏ដោយ តែដើមបណ្ដឹងរដ្ឋប្បវេណីបីនាក់បានស្នើសុំឲ្យរក្សាការសំងាត់នូវ

5. នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានអញ្ជើញមេធាវី[4]របស់ដើមបណ្តឹងរដ្ឋប្បវេណី ឲ្យដាក់សារណាទាក់ទងទៅនឹងបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន (ហៅថា"បណ្តឹងឧទ្ធរណ៍")[5] ។ ទោះបីជាមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណាបែបនេះក្តី តែនៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០០៨ ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំការអនុញ្ញាតដើម្បីចូលរួមសវនាការដែលប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ (ហៅថា"សវនាការ")[6] ។ ជាផលវិបាក អង្គបុរេជំនុំជម្រះបានផ្សព្វផ្សាយឯកសារមួយដែលមានចំណងជើងថា "ការប្រព្រឹត្តទៅនៃដំណើរការនីតិវិធីព្រហ្មទណ្ឌ" ដែលខ្លឹមសារនៃឯកសារនេះបានធ្វើការកត់សំគាល់ថាសវនាការនឹងស្តាប់សារណារបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី[7] ។

6. មេធាវីការពារក្តីរបស់លោក នួន ជា បានដាក់សំណើសុំលើកពេលសវនាការនៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨[8] ហើយអង្គបុរេជំនុំជម្រះប្រកាសថាខ្លួន នឹងស្តាប់"សារណាសុំលើកពេលសវនាការនេះ"នៅម៉ោង៩និង៣០នាទី ព្រឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨[9]។នៅសវនាការ មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអញ្ជើញឲ្យបញ្ចេញមតិយោបល់ទាក់ទងទៅនឹងសំណើនេះ-មុនលោក នួន ជា ត្រូវបានអនុញ្ញាតឲ្យនិយាយ ។ មេធាវីនីមួយៗគ្រាន់តែលើកសារឡើងវិញនូវអំណះអំណាងដែលធ្វើឡើងដោយសហព្រះរាជអាជ្ញាអ្នកស្រី ជា លាង ។ ជាលទ្ធផល សវនាការលើបណ្តឹងឧទ្ធរណ៍ត្រូវបានលើកពេលមកថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០៧ ។

7. សវនាការនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០៨ (ហៅថា"សវនាការ") បន្ទាប់ពីមានការជំទាស់ពីមេធាវីការពារក្តីរបស់លោក នួន ជា មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យធ្វើសារណាដែលជាកម្មវត្ថុនៃការជំទាស់ដោយសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះនាពេលក្រោយ ។ ដូចលើកមុនដែរ លោកមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីគ្រាន់លើកឡើងវិញនូវទឡ្ហីករណ៍របស់ការិយាល័យ

---

ទិន្នន័យរបស់ពួកគេ ។ សូមមើលឯកសារលេខ D-22/2/4, D-22/6/4 និង D-22/7/4 ។ កញ្ញា សេង មិនបានស្នើសុំបែបនេះទេ ។ សូមមើលឯកសារលេខ D-22/1/3 ។

[4] ដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននាក់ ត្រូវបានតំណាងដោយមេធាវី ។ សូមមើលឯកសារលេខ D-22/1/2, D-22/1/4, D-22/2/3, D-22/2/5/, D-22/6/3, D-22/6/5, D22/7/3 និង D-22/7/5 ។

[5] សូមមើលឯកសារលេខ C-11/17 ("ការអញ្ជើញ") ។

[6] សូមមើលឯកសារលេខ D-22/1/3, D-22/2/4, D-22/6/4 និង D-22/7/4 ។

[7] សារអេឡិចត្រូនិចរបស់អង្គបុរេជំនុំជម្រះទៅកាន់ភាគី និងអ្នកចូលរួម ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ ។

[8] សូមមើលឯកសារលេខ C-11/25 ។

[9] សូមមើលឯកសារលេខ C-11/27 "សេចក្តីជូនដំណឹងពាក់ព័ន្ធនឹងសំណើសុំលើកពេលសវនាការជាបន្ទាន់លើបណ្តឹងឧទ្ធរណ៍" នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៨ ។

សហព្រះរាជអាជ្ញា (ហៅថា"ក.ស.ព") តែប៉ុណ្ណោះ ដោយមិនបានបង្ហាញថាតើសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ បានប៉ះពាល់ដល់ផលប្រយោជន៍កូនក្តីរបស់ពួកគេយ៉ាងណានោះឡើយ ។ មានសារណាតែមួយគត់ដែលធ្វើឡើងដោយកញ្ញា សេង ធារី និយាយហួសពីគោលជំហររបស់សហព្រះរាជអាជ្ញា ដែលក្នុងនោះនាងបានចោទប្រកាន់លោក នួន ជា យ៉ាងក្តែងៗថាគាត់ត្រូវទទួលខុសត្រូវចំពោះការបាត់បង់ក្រុមគ្រួសាររបស់នាង និង អ្នកដទៃទៀត ។

## III. ច្បាប់ពាក់ព័ន្ធ

### ក. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

8. មាត្រ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[10] (ហៅថា 'CPC") ចែងថា:

បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋវេណី គឺជាបណ្តឹងពីរផ្សេងគ្នា ។

បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់ ។

បណ្តឹងរដ្ឋប្បវេណីមានគោលបំណងធ្វើឲ្យបានជួសជុលការខូចខាតដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយក្នុងគោលបំណងនេះ ឲ្យអ្នករងគ្រោះទទួលបានសំណងដម្ងៃចិត្តធួនល្មមនឹងព្យសនកម្មដែលខ្លួនបានទទួល[11] ។

9. នៅកម្ពុជា *"បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមនៃផលប្រយោជន៍ទូទៅ"*[12] ដោយអយ្យការ ។ បន្ទាប់ពីព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ជាផ្លូវការ "ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងជូនចៅក្រមស៊ើប

---

[10] កំណត់សំគាល់: ក្រមនីតិវិធីព្រហ្មទណ្ឌដែលត្រូវបានបកប្រែក្រៅផ្លូវការ ត្រូវបានយោងនៅក្នុងសារណានេះ ។

[11] ស្ថានភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានបញ្ញត្តិនៅក្នុងមាត្រា ១៣ ("បណ្តឹងរដ្ឋប្បវេណីតម្រូវឲ្យអនុវត្តដោយជនរងគ្រោះនៃបទល្មើស ។ ដើម្បីទទួលការជួសជុលបាន ព្យសនកម្មត្រូវតែ [sic]:
- ជាផលវិបាកផ្ទាល់នៃបទល្មើស
- ជាព្យសនកម្មផ្ទាល់ខ្លួន
- បានកើតឡើង និងនៅក្នុងពេលបច្ចុប្បន្ន ។ ព្យសនកម្មអាចជាព្យសនកម្ម១ខាងសម្ភារ: ខាងរូបរាងកាយ និង ផ្លូវចិត្ត។

[12] មាត្រា ៤ ក្រមនីតិវិធីព្រហ្មទណ្ឌ (សង្កត់បន្ថែម) "ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈឹម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបអង្កេត ។ សូមអានមាត្រា ៥ និង មាត្រា ១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

អង្កេត ដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី"ដោយរង់ចាំបណ្តឹងអាជ្ញា[13]។ គោលបំណងតែមួយគត់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រោមបទបញ្ញត្តិរបស់ក្រមព្រហ្មទណ្ឌ គឺការជួសជុលព្យសនកម្មនឹងត្រូវសម្រេច លុះត្រាតែតុលាការព្រហ្មទណ្ឌ"បានពិនិត្យជាមុនអំពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ហើយបានប្រកាសថាជនជាប់ចោទត្រូវមានពិរុទ្ធភាពសិន"[14]។

10. ក្រមនីតិវិធីព្រហ្មទណ្ឌចែងយ៉ាងច្បាស់អំពីដីកានានា(ដែលចេញដោយចៅក្រមស៊ើបអង្កេត) ដែលព្រះរាជអាជ្ញា ជនជាប់ចោទ និង ភាគីដើមបណ្តឹងរដ្ឋប្បវេណីអាចប្តឹងឧទ្ធរណ៍បាន[15]។ មានដីកាមួយចំនួនដែលដើមបណ្តឹងរដ្ឋប្បវេណីពុំមានសិទ្ធិប្តឹងឧទ្ធរណ៍បាន ដូចជា ដីកាឃុំខ្លួនបណ្តោះអាសន្ន ឬ ដីកាត្រួតពិនិត្យតាមផ្លូវតុលាការ[16]។ ការបណ្តឹងឧទ្ធរណ៍ប្រឆាំងលើដីកាទាំងពីរនេះត្រូវបានបំរុងទុកឱ្យព្រះរាជអាជ្ញា និងជនជាប់ចោទ[17]។ បន្ថែមពីលើនេះ ទាំងចៅក្រមស៊ើបអង្កេត និង តុលាការដំបូងមិនតម្រូវឱ្យបើកសវនាការលើសារណារបស់ដើមបណ្តឹងរដ្ឋប្បវេណីមុនបញ្ជាឱ្យដោះលែង ឬ បន្តការឃុំខ្លួនជនជាប់ចោទនោះទេ[18] តែ ចៅក្រមស៊ើបអង្កេត និង តុលាការត្រូវស្តាប់សារណារបស់ព្រះរាជអាជ្ញា និង សារណាជនជាប់ចោទសិន[19] ។ តាមការអនុវត្តជាក់ស្តែង មេធាវីការពារក្តីដឹងថា តុលាការកម្ពុជាមិនបានអនុញ្ញាតឱ្យភាគីដើមបណ្តឹងរដ្ឋវេណីចូលរួមក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នឡើយ ។

## ខ. វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក

11. វិធាន ២៣(១) ចែងថា:

គោលបំណងនៃបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បី:

(ក) ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ និង

ប៉ុន្តែ ព្រះរាជអាជ្ញាជាអ្នកផ្តើមការចោទប្រកាន់ ហើយក៏អាចរំលត់បណ្តឹងអាជ្ញាបានដែរ ។ សូមមើលមាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[13] មាត្រា ១៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[14] សូមមើលមាត្រា ២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[15] សូមមើលមាត្រា ២៦៦ ដល់ ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[16] សូមមើលមាត្រា ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[17] សូមមើលមាត្រា ២៦៦ និង ២៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[18] សូមមើលមាត្រា ២០៦ ២០៧ ២១១ ២១៥ ២១៦ ៣០៦ និង ៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[19] ដូចខាងលើ ។

(ខ) អនុញ្ញាតឲ្យជនរងគ្រោះអាចស្វែងរកសំណងផ្លូវចិត្ត និង សម្ភារភាព ដូចមានចែងនៅក្នុងវិធាននេះ ។

12. អនុលោមទៅតាមវិធានផ្ទៃក្នុង មានតែសហព្រះរាជអាជ្ញាទេអាចផ្តួចផ្តើមដំណើរការនីតិវិធីព្រហ្មទណ្ឌ ទោះបី "ជាការសម្រេចចិត្តដោយខ្លួនឯង ឬ ដោយផ្អែកតាមពាក្យបណ្តឹងក៏ដោយ"[20]។ សិទ្ធិរបស់ជនរងគ្រោះក្រោមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[21]ដើម្បីធ្វើបណ្តឹងអាជ្ញាមិនមានបញ្ញត្តិនៅក្នុងវិធាននេះទេ។ ប៉ុន្តែ នៅពេលកិច្ចការស៊ើបអង្កេតដោយតុលាការបានចាប់ផ្តើម ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងទៅសហចៅក្រមស៊ើបអង្កេតដើម្បីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[22] ។

13. ទាក់ទិនទៅនឹងបញ្ហាប្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញមានខ្លឹមសារដូចគ្នាទាំងស្រុងនឹងបទប្បញ្ញត្តិរបស់ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ វិធាន ៧៤(៤) ផ្តល់បញ្ជីដីកាដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យប្តឹងឧទ្ធរណ៍ តែមិនរាប់បញ្ចូលនូវដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្ន ដីកាបញ្ជាឲ្យដោះលែងបណ្តោះអាសន្ន ឬ ដីកាសម្រេចឲ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការទេ ។ បន្ថែមពីលើនេះ វិធាន ៨២(៥) ចែងថា: "សេចក្តីសម្រេចទាំងអស់របស់អង្គជំនុំជម្រះសាលាដំបូងអាចត្រូវប្តឹងសាទុក្ខដោយជនជាប់ចោទ ឬ សហព្រះរាជអាជ្ញា តាមករណីចាំបាច់" ។ ដើមបណ្តឹងរដ្ឋប្បវេណីពុំមានសិទ្ធិបែបនេះទេ ។

## គ. ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ

14. ក្រៅពី អ.វ.ត.ក មានតែតុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") មួយគត់ដែលអនុញ្ញាតឲ្យមានការចូលរួមពីសំណាក់ជនរងគ្រោះ។ ទាក់ទិននឹងចំនុចនេះ មាត្រា ៦៨(៣) នៃច្បាប់លក្ខន្តិកៈទីក្រុងរ៉ូម ចែងថា:

> កាលណាផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះត្រូវប៉ះពាល់ តុលាការត្រូវអនុញ្ញាតឲ្យគេបញ្ចេញទស្សនៈ និងកង្វល់ និងត្រូវយកទស្សនៈ និងកង្វល់ទាំងនោះមកពិចារណានៅក្នុងដំណាក់កាលនានានៃដំណើរការនីតិវិធី ដែលត្រូវបានតុលាការកំណត់ថាសមស្រប និងនៅក្នុងលក្ខណៈមួយដែលមិនមានលក្ខណៈអគតិ ឬមិនមានលក្ខណៈមិនស្របជាមួយសិទ្ធិរបស់ជនជាប់ចោទ និងការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងឥតលំអៀង [...] ។

---

[20] វិធាន ៤៩(១) ។

[21] សូមមើលមាត្រា ៥ និង មាត្រា១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[22] សូមមើលវិធាន ២៣(៣) ។

នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ(ICC) ជនរងគ្រោះមិនមានសិទ្ធិចូលរួមជាស្វ័យប្រវត្តិនៅក្នុងរឿងបណ្តឹងឧទ្ធរណ៍បានទេ។ ផ្ទុយទៅវិញ ពួកគេត្រូវសុំការអនុញ្ញាតសម្រាប់ការចូលរួមបែបនេះ[23]។

15. ក្នុងការវាយតំលៃទៅលើវិសាលភាពនៃមាត្រា ៦៨(៣) អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានសម្រេចថា វាជាបន្ទុករបស់ជនរងគ្រោះក្នុងការបង្ហាញឲ្យឃើញ (i)"ថាតើផលប្រយោជន៍ផ្ទាល់ខ្លួន[របស់ពួកគេ]ត្រូវបានប៉ះពាល់ដោយការប្តឹងឧទ្ធរណ៍ដែរឬទេនោះ"[24] និង

---

[23] *សូមមើល រដ្ឋអាជ្ញា ទល់នឹង* *Thomas Lubanga Dyilo* សំណុំរឿងលេខ ICC-01/04-01/06, AC "សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំ ជម្រះ I" ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ ("សាលដីកា Lubanga ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧") កឋាខ័ណ្ឌ ៣៨ ដល់ ៤០ ។ ចំនុចនេះគឺយោងទៅលើភាសាដែលច្បាស់លាស់ក្នុងមាត្រា ៨២(១)(ខ)នៃលក្ខន្តិកៈទីក្រុងរ៉ូមដែលបានចែងសម្រាប់ការប្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញា និងមេធាវីការពារ ដែលទាក់ទងទៅនឹងសិទ្ធិៈ "*ភាគីទាំងពីរ*អាចប្តឹងជំទាស់ [...] [a] សេចក្តីសម្រេចផ្តល់ ឬ បដិសេធចំពោះការដោះលែងជនដែលកគំពុងត្រូវរងការស៊ើបអង្កេត ឬ កំពុងត្រូវនាំយកមកជំនុំជម្រះ"។ (បញ្ជាក់បន្ថែម) *សូមមើល* Jorda និង de Hemptinne *ផងដែរ* "ស្ថានភាព និងតួនាទីរបស់ជនរងគ្រោះ" នៅក្នុង Cassese et al (eds)។ លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិៈ សេចក្តីអត្ថាធិប្បាយ Vol II ទំព័រ ១៤០៦ (ជនរងគ្រោះ "មិនមានសិទ្ធិប្តឹងឧទ្ធរណ៍ ហើយយោងតាមមូលដ្ឋាននេះ មិនអាចបង្ហាញនូវទឡ្ហីករណ៍របស់ខ្លួនប្រឆាំងលើជនជាប់ចោទនៅចំពោះមុខអង្គជំនុំជម្រះតុលាការតកំពូលបានទេ")។ *សូមមើល* Roth និង Henzeline *ផងដែរ* "នីតិវិធីប្តឹងឧទ្ធរណ៍របស់ ICC" នៅក្នុង Cassese et al (op. cit) ទំព័រ ១៥៥១ ("ជនរងគ្រោះ និង ភាគីរដ្ឋប្បវេណី និងតតីយភាគី ដែលប៉ះពាល់ដោយសេចក្តីសម្រេចនេះ តាមធម្មតាក្នុងន័យចង្អៀត ដោយយោងតាមមាត្រា ៨២ មិនអាចចាត់ទុកថាជាភាគីចំពោះការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចជាបណ្តោះអាសន្នបានទេ លើកលែងតែសេចក្តីសម្រេចបែបនោះធ្វើឲ្យប៉ះពាល់ដល់សិទ្ធិពលរដ្ឋរបស់ពួកគេ ដូចមានចែងក្នុងមាត្រា ៨២(៤)/មាត្រា ៧៥")។

[24] ស្ថានភាពនៅក្នុងសាធារណៈរដ្ឋប្រជាមានិតកុងហ្គោ រឿងក្តីលេខ ICC-01/04 "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើសំណើតរបស់ OPCV ស្នើសុំឲ្យមានការបញ្ជាក់ និងតំណាងស្របច្បាប់" សំណើសុំពន្យារពេល និងដីកាបង្គាប់របស់អង្គជំនុំជម្រះតុលាការកំពូលស្តីពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំការចូលរួម និងស្តីពីពេលវេលា នៃការដាក់សារណាឆ្លើយតបដោយ OPCD និង *រដ្ឋអាជ្ញា*" ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨ ("សេចក្តីសម្រេច DRC ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨ កឋាខ័ណ្ឌ១ ។ កំណត់សំគាល់"មានឧទាហរណ៍យ៉ាងជាក់ច្បាស់ជាច្រើនថាតើផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ជនរងគ្រោះត្រូវបានប៉ះពាល់នៅត្រង់ណានោះ គឺនៅពេលដែលការការពារខ្លួនរបស់ពួកគេចិតនៅក្នុងបញ្ហា និងជាប់ពាក់ព័ន្ធទៅនឹងដំណើរការនីតិវិធីសម្រាប់ការទាមទារសំណង"។ *រដ្ឋអាជ្ញា តទល់នឹង Thomas Lubanga Dyilo* សំណុំរឿងលេខ ICC-01/04-01/06, AC "សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើបណ្តឹងរួមគ្នារបស់ជនរងគ្រោះ a/0001/06 ដល់ a/0003/06 និង a/0105/06" ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ ("សេចក្តីសម្រេច Lubanga ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧") កឋាខ័ណ្ឌ ២៨ (សម្រេចថា ជនរងគ្រោះពុំបានបង្ហាញឲ្យឃើញពីផលប្រយោជន៍នៅក្នុងការសាកសួរជាបឋមថាតើការប្តឹងឧទ្ធរណ៍ស្នើសុំការបញ្ជាក់ពីបទចោទ នោះបានធ្វើឡើងត្រឹមត្រូវដែរឬទេ) ។

(ii)"ថាតើហេតុអ្វីបានជាវាមានលក្ខណៈសមស្រប សម្រាប់ឲ្យអង្គជំនុំជម្រះតុលាការកំពូលអនុញ្ញាតឲ្យពួកគេបញ្ចេញទស្សនៈ និងកង្វល់នៅក្នុងដំណាក់កាល[ជាក់លាក់]នៃដំណើរការនីតិវិធី"[25] និង(iii) "ថាហេតុអ្វីបានជាការបង្ហាញនូវទស្សនៈ និងកង្វល់ទាំងនោះនឹងមិនប៉ះពាល់ដល់ ឬមិនសមស្រប ជាមួយសិទ្ធិរបស់ជនជាប់ចោទនោះ"[26]។

16. ទាក់ទិនទៅនឹងការប្តឹងឧទ្ធរណ៍ជំទាស់នឹងការឃុំខ្លួនបណ្តោះអាសន្ន "[ការ]ចូលរួមរបស់ជនរងគ្រោះត្រូវតែមានដែនកំណត់ និង[...] ជាប់ពាក់ព័ន្ធជាក់លាក់ទៅនឹងបញ្ហាដែលកើតចេញពីការប្តឹងឧទ្ធរណ៍ជាជាងបញ្ហាជាទូទៅ"[27]។ និយាយឲ្យចំ "វាមិនមានលក្ខណៈសមស្របនោះទេដោយការគ្រាន់តែលើកឡើងដដែលៗពីភស្តុតាងនៅចំពោះមុខអង្គបុរេជំនុំជម្រះ ឬការបង្ហាញភស្តុតាងថ្មីៗនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដោយមិនបានភ្ជាប់ទំនាក់ទំនងជាក់លាក់ណាមួយ ថាតើមានការប៉ះពាល់ប៉ុណ្ណាដល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើបញ្ហា ដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នោះ"[28]។

17. ទោះបីជាក្នុងករណី ដែលជនរងគ្រោះបានបំពេញនូវបន្ទុកលើកដំបូងរបស់ខ្លួនដោយការបង្ហាញឲ្យឃើញនូវផលប្រយោជន៍ចាំបាច់ផ្ទាល់ខ្លួន ភាពសមស្របនៃការចូលរួមរបស់ពួកគេ និងការមិនបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទក៏ដោយ ក៏សារណារបស់ពួកគេអាចនៅតែមិនមានសារៈប្រយោជន៍ដដែល" ។

> ក្នុងខណៈដែលអង្គជំនុំជម្រះតុលាការកំពូលបានកត់សំគាល់ពីការព្រួយបារម្ភ ដែលបានលើកឡើងដោយជនរងគ្រោះជាប់ពាក់ព័ន្ធទៅនឹងអ្វីដែលពួកគេបានចោទប្រកាន់អាចនឹងកើតមានឡើង ប្រសិនបើចុងចោទត្រូវបានដោះលែងជាបណ្តោះអាសន្ន វាពុំត្រូវបានរកឃើញថា ពួកគេបានផ្តល់ជំនួយនៅក្នុងការសម្រេចទៅលើមូលហេតុជាក់លាក់នៅចំពោះមុខខ្លួននៅក្នុងបណ្តឹងឧទ្ធរណ៍នាពេលនេះ និងហេតុនេះហើយ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនទៅលើខ្លឹមសារនៃបណ្តឹងឧទ្ធរណ៍នាពេលនេះមិនបានយោងទៅលើការព្រួយបារម្ភទាំងនោះទេ[29] ។

---

[25] សេចក្តីសម្រេច DRC ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៨ កឋាខ័ណ្ឌ ១ ។

[26] ដូចខាងលើ ។

[27] សាលដីកា Lubanga ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ កឋាខ័ណ្ឌ ៥៥ ។

[28] ដូចខាងលើ កឋាខ័ណ្ឌ ៧១ ។

[29] ដូចខាងលើ កឋាខ័ណ្ឌ ៧២ ។

18. តាមការពិត នៅក្នុងរឿងក្តីទាំងអស់"ការវាយតម្លៃនឹងត្រូវបានធ្វើឡើង [...]ថាតើផលប្រយោជន៍ដែលបានអះអាងដោយជនរងគ្រោះ វាឋិតនៅក្រៅផលប្រយោជន៍ផ្ទាល់ខ្លួន ហើយម្យ៉ាងវិញទៀតវាជាតួនាទីរបស់រដ្ឋអាជ្ញាឬយ៉ាងណានោះ"[30]។

## IV. ទឡ្ហីករណ៍

### ក. អង្គបុរេជំនុំជម្រះពុំមានយុត្តាធិការអញ្ជើញ ឬ អនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទេ

19. ការអញ្ជើញភាគីរដ្ឋប្បវេណី បង្ហាញឱ្យឃើញថាអង្គបុរេជំនុំជម្រះ"បានទទួលការទទួលស្គាល់ជាផ្លូវការពីសហចៅក្រមស៊ើបអង្កេត ទាក់ទងទៅនឹងពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ*ត្រូវបានអនុម័ត*"[31]។ ប៉ុន្តែ មេធាវីការពារក្តីមិនបានដឹងអំពីការអនុម័តបែបនេះរបស់សហចៅក្រមស៊ើបអង្កេតទេ តែមេធាវីការពារក្តីបានទទួលសំណៅលិខិតបញ្ជូនទៅអ្នកដាក់ពាក្យសុំបួននាក់ពីលោក លី ចាន់តុលា ក្រឡាបញ្ជីនៃ ក.ស.ច.ស[32] ។ ខ្លឹមសារនៃលិខិតរបស់លោក លី ចាន់តុលា មិនបាននិយាយពីការសម្រេចជាផ្លូវការរបស់សហចៅក្រមស៊ើបអង្កេតលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ ។ ផ្ទុយទៅវិញ ខ្លឹមសារនៃលិខិតនេះគូសបញ្ជាក់ថា ពុំមានការសម្រេចបែបនេះនៅឡើយទេ០:

> សូមជម្រាបថាសហចៅក្រមស៊ើបអង្កេតអាចសម្រេចជាផ្លូវការនៅដំណាក់កាលណាមួយនៃកិច្ចស៊ើបអង្កេតលើការទទួលយកពាក្យសុំតាំងខ្លួនដើមបណ្តឹងរដ្ឋប្បវេណីរបស់អ្នក ឬ បដិសេធពាក្យសុំ ប្រសិនបើសហចៅក្រមស៊ើបអង្កេតយល់ឃើញថាអ្នកមិនមែនជាជនរងគ្រោះ ឬពាក្យសុំរបស់អ្នកមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយវិធានផ្ទៃក្នុង និង សេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងគ្រោះ[33] ។

20. មេធាវីការពារក្តីស្នើសុំថានីតិវិធីបែបនេះមិនអាចទទួលយកបានឡើយ។ អនុលោមតាមបទបញ្ញត្តិនៃវិធានផ្ទៃក្នុង ការអនុវត្តបែបនេះហាក់ដូចជាថាអ្នកដាក់ពាក្យសុំនេះត្រូវបានទទួលស្គាល់ជាដើមបណ្តឹង

---

[30]សាលដីកា Lubanga ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ កឋាខ័ណ្ឌ ២៨ ។ (សម្រេចថា ជនរងគ្រោះពុំបានបង្ហាញឱ្យឃើញពីផលប្រយោជន៍នៅក្នុងការសាកសួរបឋមថាតើការប្តឹងឧទ្ធរណ៍ស្នើសុំការបញ្ជាក់ពីបទចោទនោះបានធ្វើឡើងត្រឹមត្រូវដែរឬទេ)

[31] ឯកសារលេខ C-11/7 (បញ្ជាក់បន្ថែម) ។

[32] សូមមើលឯកសារលេខ D-22/1/1, D-22/2/2, D-22/6/2 និង D-22/7/2 ។

[33] ឯកសារលេខ C-11/7 (បញ្ជាក់បន្ថែម) ។

រដ្ឋប្បវេណីមុនមានសេចក្ដីសម្រេចពីសហចៅក្រមស៊ើបអង្កេតរួចទៅហើយ[34]។ បន្ថែមពីលើនេះទៀត ប្រសិនបើសហចៅក្រមស៊ើបអង្កេតមានបំណងរក្សាទុកពាក្យសុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី រង់ចាំការត្រួតពិនិត្យជាក្រោយ នោះក្រឡាបញ្ជីមិនត្រូវទទួលស្គាល់ពួកគេជាបណ្ដោះអាសន្នទេ។ អនុលោមទៅតាមវិធានផ្ទៃក្នុង មុននឹងមានការទទួលស្គាល់ថាជាដើមបណ្ដឹងរដ្ឋប្បវេណីរួមបាន លុះត្រាតែពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានត្រួតពិនិត្យ និង សម្រេចដោយសហចៅក្រមស៊ើបអង្កេតដោយផ្ទាល់[35]។ ដោយសារតែបញ្ហានេះមិនបានទាន់កើតឡើងនៅឡើយ ហេតុដូច្នេះអង្គបុរេជំនុំជម្រះពុំមានយុត្តាធិការអញ្ជើញដើមបណ្ដឹងរដ្ឋប្បវេណីឱ្យចូលរួមក្នុងរឿងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ឬ អនុញ្ញាតឱ្យពួកគេចូលរួមបានទេ ។

## ខ. ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន មិនត្រូវបានអនុញ្ញាតដោយច្បាប់កម្ពុជា និង វិធានផ្ទៃក្នុងឡើយ

21. ទាំងក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានផ្ទៃក្នុង មានបទបញ្ញត្តិពាក់ព័ន្ធជាមួយគោលបំណងចូលរួមក្នុងដំណើរការនីតិវិធីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានចែងយ៉ាងច្បាស់ពីគោលជំហរបន្ទាប់បន្សំនៃការចូលរួមបែបនេះ បើប្រៀបធៀបជាមួយបណ្ដឹងអាជ្ញា។ ក្រមនីតិវិធីព្រហ្មទណ្ឌចែងយ៉ាងច្បាស់ថាបណ្ដឹងរដ្ឋប្បវេណីកំណត់ត្រឹមតែសំណងជម្ងឺចិត្ត និងព្យសនកម្ម[36]តែប៉ុណ្ណោះ។ ទោះបីវិធានផ្ទៃក្នុងបញ្ជាក់ពីគោលបំណងបន្ថែមសម្រាប់“គាំទ្រដល់ការចោទប្រកាន់”[37] ហើយពាក្យពេចន៍ទូទៅត្រូវតែបានបកស្រាយស្របតាមស្មារតីនៃបទប្បញ្ញត្តិស្ដីពីការប្ដឹងឧទ្ធរណ៍ ដែលដើមបណ្ដឹងរដ្ឋប្បវេណីមិនមានសិទ្ធិចូលរួមក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្ដោះអាសន្នឡើយ[38] ។

22. ជាជាងការទទួលស្គាល់នូវសិទ្ធិទូទៅ ដើម្បីចូលរួមគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីបានដោយគ្មានការដាក់កំហិត វិធាន២៣(១)(ក) គ្រាន់ទទួលស្គាល់ដ៏សាមញ្ញនូវតួនាទីគាំទ្ររបស់

---

[34] វិធាន ២៣(២) កំណត់ពីលក្ខណៈវិនិច្ឆ័យសំរាប់ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយ វិធាន ២៣(៥) ចែងលំអិតពីព័ត៌មានចាំបាច់ដើម្បីគាំទ្រដល់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ។

[35] វិធាន ២៣(៣) តម្រូវឱ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីសក្ដានុពល “ដាក់ពាក្យបណ្ដឹងទៅសហចៅក្រមស៊ើបអង្កេត” ការបកស្រាយលើពាក្យពេចន៍ដ៏សមហេតុផល គឺថា "មានតែចៅក្រមស៊ើបអង្កេតទេ ដែលត្រូវសម្រេចលើពាក្យសុំនេះ” ។

[36] មាត្រា ២ ក្រមនីតិវិធីព្រហ្មទណ្ឌ ។

[37] វិធាន ២៣(១)(ក) ។

[38] អនុលោមទៅតាមគោលការណ៍ *Lex specialis derogate generali* បទប្បញ្ញត្តិទូទៅរបស់វិធាន ២៣(១)(ក) ត្រូវទាត់ចោលដោយគោលការណ៍ *Lex specialis* នេះ ជាពិសេសដោយមាត្រា ២៦៦ ដល់ ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធាន ៧៤(៤) និង ៨៤(៥) ។

ដើមបណ្តឹងរដ្ឋប្បវេណីតែប៉ុណ្ណោះ[39]។ ពាក្យពេចន៍បន្ថែមនេះអាចត្រូវបានយល់ថាជាសំដីបញ្ជោរ បន្ថែមបន្ថយដល់សមត្ថភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីផ្តើមបណ្តឹងអាជ្ញាដោយប្រយោល ដែលត្រូវផ្តន្ទាទោសនៅក្រោមក្រមនីតិវិធីព្រហ្មទណ្ឌ ដែលជាសញ្ញាណត្រូវបានទាត់ចោលយ៉ាងច្បាស់ ត្រឡែកដោយអ្នកព្រាងវិធានផ្ទៃក្នុងនេះ ។

23. ការហាមឃាត់ដើមបណ្តឹងរដ្ឋប្បវេណីដើម្បីចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន គឺបានឆ្លុះបញ្ចាំពីការអនុវត្តជាក់ស្តែងនៅតុលាការកម្ពុជា។ ដោយសារតែការរឹតត្បឹតបែបនេះមិនមែនថាមិនស្របតាមនិយាមអន្តរជាតិនោះទេ ហេតុដូច្នេះ គេមិនចាំបាច់ពិនិត្យពិចារណាលើការអនុវត្ត និងគោលការណ៍អន្តរជាតិ ឲ្យលើសពីក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានឡើយ[40]។ អ្នកធ្វើអត្ថាធិប្បាយមួយរូបបានធ្វើការកត់សំគាល់ទាក់ទងទៅនឹងការចូលរួមទូទៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីថា:"ដំណោះស្រាយត្រូវតែស្របតាមប្រព័ន្ធច្បាប់ស៊ីវិលនៅកម្ពុជា ហើយមិនត្រូវប្រើប្រាស់ឱកាសនេះដើម្បីបញ្ចូលវិធានរបស់តុលាការអន្តរជាតិនោះឡើយ[41] ។

## ខ. ដើមបណ្តឹងរដ្ឋប្បវេណីខកខានបង្ហាញផលប្រយោជន៍របស់ពួកគេនៅក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

24. ឧបមាថាអង្គបុរេជំនុំជម្រះគិតថាខ្លួនត្រូវពិនិត្យឲ្យលើសពីច្បាប់កម្ពុជា អង្គបុរេជំនុំជម្រះគួរពិនិត្យទៅលើយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ។ លក្ខខណ្ឌតម្រូវនានាសម្រាប់ការចូលរួមរបស់ជនរងគ្រោះ នៅក្នុងដំណើរការនីតិវិធីផ្សេងៗ ស្របជាមួយសញ្ញាណនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដូចមានចែងនៅក្នុងវិធាន ២៣(១)(ក) ដែលចាំបាច់ (ជាបញ្ញាកត្តវិជ្ជា) ត្រូវបង្ហាញនូវផលប្រយោជន៍ជាមុនដែលកើតចេញពីលទ្ធផលនៃដំណើរការនីតិវិធីទាំងនោះ ។ និយាយសាមញ្ញទៅការចូលរួមរបស់ជនរងគ្រោះក្នុងដំណើរការនីតិវិធីដែលពួកគេពុំមានផលប្រយោជន៍ទាល់សោះនោះ គឺមិនត្រូវអនុញ្ញាតឡើយ ។

25. មកដល់ពេលនេះ អង្គបុរេជំនុំជម្រះមិនបានបង្គាប់ឲ្យដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញផលប្រយោជន៍បែបនេះទេ ហើយពួកគេក៏មិនបានបង្ហាញផលប្រយោជន៍តាមគំនិតផ្តួចផ្តើមរបស់ខ្លួនដែរ ។ ដូចបានកត់សំគាល់ខាងលើ មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីគ្រាន់តែគូសបញ្ជាក់សារឡើងវិញនូវជំហ៊រ

[39] ម្យ៉ាងវិញទៀត វិធានកំណត់ពីគោលបំណង ប៉ុន្តែមិនបានកំណត់ពីវិសាលភាពនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[40] សូមមើលមាត្រា ៣៥ ថ្មីនៃច្បាប់ អ.វ.ត.ក ។

[41] David Boyle "សិទ្ធិរបស់ជនរងគ្រោះ៖ ការចូលរួម ការតំណាង ការការពារ និង សំណងជួសជុលជម្ងឺចិត្ត" ព្រឹត្តិប័ត្ររបស់យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ចុះផ្សាយនៅខែឧសភា ឆ្នាំ២០០៦ ។ 4.J. Int"l Crim. Just.307,309.

របស់សហព្រះរាជអាជ្ញា។ ពុំមានភាគីដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ក្នុងចំណោមពួកគេទាំងបួន បង្ហាញថាតើផលប្រយោជន៍របស់ខ្លួនត្រូវបានប៉ះពាល់ដោយបណ្តឹងឧទ្ធរណ៍នេះយ៉ាងដូម្តេចនោះទេ ។ នេះគឺជាតម្រូវការយ៉ាងពិតប្រាកដក្រោមយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលបាន រិះគន់យ៉ាងធំៗចំពោះការដាក់សារណាច្រំដែលៗដែលធ្វើឡើងដោយជនរងគ្រោះ[42] ។

26. ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីបានលើកពីផលប្រយោជន៍ណាមួយនៅសវនាការ ផលប្រយោជន៍ទាំងនោះត្រូវតែបានចែកដោយសាធារណៈជនដទៃទៀតដែរ បើអញ្ចឹងមែន វាមិនមែនជាផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីតែឯងទេ។ ហេតុដូច្នេះ សហព្រះរាជអាជ្ញាមានសមត្ថភាពដោះស្រាយនូវការព្រួយបារម្ភនេះ ដោយសារតែពួកគេមានតួនាទីអនុវត្តបណ្តឹងអាជ្ញាក្នុងនាម "ផលប្រយោជន៍ទូទៅ"[43] ហើយនៅក្នុងករណីនេះ ភារកិច្ចនេះក៏មិនចាំបាច់មានការជួយគាំទ្រពីដើមបណ្តឹងរដ្ឋប្បវេណីដែរ[44]។

**គ. ការចូលរួមរបស់ភាគីរដ្ឋប្បវេណីនៅក្នុងរឿងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការសម្រេចឃុំខ្លួនបណ្តោះអាសន្នមិនសមស្របជាមួយសិទ្ធិរបស់ជនត្រូវចោទ និង ការអនុវត្តជាក់ស្តែងរបស់ អ.វ.ត.ក ទេ**

27. នៅក្នុងការសម្រេចបញ្ហានេះ អង្គបុរេជំនុំជម្រះត្រូវយល់ពីសក្តានុពលសម្រាប់ការចូលរួមពីសំណាក់ភាគីរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក ក្នុងការធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់ (i) សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងដោយគ្មានការអូសបន្លាយ (ii) គោលការណ៍សមភាពនៃគូភាគី និង (iii) សច្ចធារណ៍នៃនិរទោស។ អង្គបុរេជំនុំជម្រះបានទទួលឱកាសដើម្បីធានាថា សិទ្ធិជាមូលដ្ឋានទាំងនេះមិនត្រូវរំលោភទៅនឹងការពិចារណាជានិម្មិតរូប និង/ឬជាប្រវត្តិសាស្ត្របែបអរូបីនៃការចូលរួមពីសំណាក់ភាគីរដ្ឋប្បវេណីនោះទេ[45] ។

---

42 សូមមើលសាលក្រមលើរឿងក្តី Lubanga ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ កថាខណ្ឌ ៧១ ។

43 មាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ(បញ្ជាក់បន្ថែម) ។ សូមមើលសាលក្រមរឿងក្តី Lubanga ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ២៨ ។

44 សូមមើលវិធាន ២៣(១)(ក) ។ កណត់សំគាល់៖ ច្បាប់មិនទទួលស្គាល់សិទ្ធិដើម្បីសងសឹកាបុគ្គលទេ ។

45 *សូមមើល ឧទាហរណ៍* ឯករាជ្យ "ក្រោយពីរយៈពេល ៣០ ឆ្នាំ ជនរងគ្រោះនៃរបបខ្មែរក្រហមបានប្រឈមមុខនឹងមេដឹកនាំនៅក្នុងតុលាការ" ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៨ ("វាជានិម្មិតរូបដ៏សំខាន់" ប្រសាសន៍របស់ Peter Foster ដែលជានាំពាក្យសាលាក្តីខ្មែរក្រហម។ "យើងបានបង្កើតថ្ងៃប្រវត្តិសាស្ត្រ" សេវាព័ត៌មាន អ.ស.ប "ជនរងគ្រោះក្នុងរបបខ្មែរក្រហមចូលរួមនៅក្នុង"ថ្ងៃប្រវត្តិសាស្ត្រ" នៅឯសាលាក្តីដែលគាំទ្រដោយ អ.ស.ប" កាលពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨

28. ដោយនិយាយមិនឱ្យលើសលប់ពេកទេ ជាទូទៅ នៅក្នុងបរិបទដែលបទល្មើសមានទ្រង់ទ្រាយធំ ហើយជាពិសេស បទល្មើសដែលត្រូវបានចោទប្រកាន់ថាបណ្តាលឱ្យមានជនរងគ្រោះរហូតដល់ទៅរាប់លាននាក់ បង្កឱ្យមានការព្រួយបារម្ភថា ការដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាភាគីរដ្ឋប្បវេណីពីចំណោមមហាជនដ៏ច្រើនលើសលប់នាំឱ្យមានការយឺតយ៉ាវយ៉ាងខ្លាំងដល់ភាពជឿនលឿននៃដំណើរការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌឱ្យបានឆាប់រហ័ស។ ការនេះអាចរំលោភបំពានដល់សិទ្ធិជាមូលដ្ឋានរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះដោយគ្មានការអូសបន្លាយ[46]។ ដំណើរការសវនាការគឺបានបង្ហាញនៅត្រង់ចំនុចនេះឯង។ តុលាការបានចំណាយពេលវេលាជាច្រើនម៉ោងទៅលើការសារណាដ៏វែងដែលមិនបានងាកចេញឆ្ងាយពីជំហររបស់ ក.ស.ព នោះទេ ។ ដោយសារភាគីរដ្ឋប្បវេណីបានត្រូវការពេលវេលាច្រើនបែបនេះដើម្បីលើកឡើងពីសំណើតែមួយ ឬសំណើបែបប្រលោមលោកដែលបញ្ជាក់ពីផលប្រយោជន៏ពិសេសរបស់ខ្លួននៅក្នុងសវនាការ នោះមេធាវីការពារពិបាករកពេលវេលាដើម្បីបង្ហាញទឡ្ហីករណ៏របស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ កំណត់ត្រានឹងបង្ហាញឱ្យឃើញថារយៈពេលស្ទើរតែពីរម៉ោងត្រូវបានចំណាយតែទៅលើការតវ៉ាដដែលៗដែលបានលើកឡើងពីមុនៗមករួចមកហើយ។

29. លើសពីនេះទៅទៀត ការចូលរួមដ៏ទូលំទូលាយរបស់ភាគីរដ្ឋប្បវេណីនៅគ្រប់ដំណាក់កាលនៃនីតិវិធីបានគំរាមកំហែងដាក់បន្ទុកដោយអយុត្តិធម៌មកលើជនត្រូវចោទ ដើម្បីឱ្យឆ្លើយតបទៅនឹងគូវិវាទដែលមានចំនួនដ៏ច្រើន។ ទោះជាយ៉ាងណាក៏ដោយ ក្រៅពីការលើកឡើងនូវទឡ្ហីករណ៏ដដែលៗ មេធាវីរបស់លោក នួន ជា ត្រូវបានតម្រូវឱ្យវាយតំលៃលើសារណាមុនៗរបស់មេធាវីរបស់ភាគីរដ្ឋប្បវេណីទាំងបីនិងកញ្ញា សេង ធារី (ខ្លួននាងផ្ទាល់ក៏ជាមេធាវីវិជ្ជាជីវៈដែរ) និង ពិចារណាថាតើត្រូវដាក់សារណាឆ្លើយតបបន្តទៀតឬយ៉ាងណា។ ជាមួយនឹងសក្តានុពលសម្រាប់បណ្តឹងរដ្ឋប្បវេណីរាប់ពាន់ច្បាប់នៅចំពោះមុខ អ.វ.ត.ក គេអាចគ្រាន់តែឆ្ងល់ថាតើមេធាវីការពារនឹងចាត់ចែងដោយរបៀបណា ប្រសិនបើ អង្គបុរេជំនុំជម្រះបន្តចេញដីកាក្នុងលក្ខណៈជាការអញ្ជើញដោយបើកចំហដ៏ទូលំទូលាយនោះ[47]។

30. ជាទីបញ្ចប់ ការចូលរួមរបស់ជនរងគ្រោះដោយគ្មានដែនកំណត់បែបនេះនឹងនាំឱ្យមានផលអាក្រក់ក្នុងការដាក់បញ្ចូលឯកសារដែលមិនជាប់ពាក់ព័ន្ធ និងដែលមានលក្ខណៈអគតិដល់ដំណើរការនីតិវិធីយ៉ាង

---

(“តាមរយៈមេធាវីការពាររបស់ពួកគេ ការចូលរួមរបស់[ជនរងគ្រោះ]ត្រូវបានផ្នែកការពារជនរងគ្រោះរបស់សាលាក្តីរៀបរាប់ថាជា “ថ្ងៃប្រវត្តិសាស្ត្រនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ”)។

[46] សូមមើលច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៥(គ) ថ្មី ។

[47] សូមមើល ក. ៥ ខាងលើ ។

ខ្លាំង។ នៅឯសវនាការ កញ្ញា សេង ធារី ធ្វើអត្ថាធិប្បាយតែអំពីពិរុទ្ធភាពរបស់លោក **នួន ជា**[48] ជាជាងការលើកបញ្ហាណាមួយពាក់ព័ន្ធទៅនឹងបណ្តឹងឧទ្ធរណ៍ ជាពិសេស សារណា របស់កញ្ញាតែមុតងដែលបង្ហាញពីតម្រូវការឲ្យអង្គបុរេជំនុំជម្រះ ធានាថាការដាក់សារណារបស់ភាគីរដ្ឋប្បវេណី គឺមានការពាក់ព័ន្ធ និងស្របជាមួយសិទ្ធិរបស់ជនត្រូវចោទ។ ទោះបីជាភាគីរដ្ឋប្បវេណីអាចទទួលបានតួនាទីមានកម្រិតនៅក្នុងដំណើរការនីតិវិធីជាក់លាក់របស់ អ.វ.ត.ក ក៏ដោយ វាក៏ត្រូវបានលើកឡើងថាការព្រួយបារម្ភ*ជាចំបង*របស់តុលាការនេះ គឺការផ្តន្ទាទោសផ្នែកព្រហ្មទណ្ឌមកលើជនត្រូវចោទឲ្យស្របតាមច្បាប់កម្ពុជា[49]។ ជាចុងក្រោយនេះ មេធាវីការពារសូមស្នើថា ទោះជាការលើកឡើងរបស់កញ្ញា សេង ធារី អស់ពីដួងចិត្តក៏ដោយ តែវាបានប្រឆាំងយ៉ាងខ្លាំងទៅនឹងការចូលរួមរបស់ភាគីរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនជាបណ្តោះអាសន្ន។

## V. សេចក្តីសន្និដ្ឋាន

31. សម្រាប់ហេតុផលដែលបានលើកឡើងខាងលើ មេធាវីការពារសូមស្នើឲ្យអង្គបុរេជំនុំជម្រះ (i) ដកសារណារបស់ភាគីរដ្ឋប្បវេណីចេញពីសំណុំរឿងបណ្តឹងឧទ្ធរណ៍របស់លោក **នួន ជា** និង (ii) បដិសេធរាល់ការចូលរួមពីសំណាក់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីណាមួយទាក់ទងទៅនឹងការឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃអនាគត ដោយអនុលោមតាមច្បាប់កម្ពុជា និង វិធានផ្ទៃក្នុង ។

**មេធាវីរបស់លោក នួន ជា:**

លោក សុន អរុណ p.p លោក Michiel PESTMAN និងលោក Victor LOPPE

[48] ឯកសារ "ក្រោយពីរយៈពេល ៣០ ឆ្នាំ ជនរងគ្រោះនៃរបបខ្មែរក្រហមបានជួបមុខមេដឹកនាំនៅក្នុងតុលាការ" នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៨ ("ប្រសិនបើ **នួន ជា** បដិសេធមិនទទួលខុសត្រូវ តើអ្នកណាជាអ្នកធ្វើឲ្យបាត់បង់ឪពុកម្តាយរបស់ខ្ញុំ និងអ្នកជាទីស្រលាញ់ជាច្រើនរបស់ជនរងគ្រោះដទៃទៀត? [...] អ្វីដែលយើងដឹងនោះគឺថា **នួន ជា** ជាមេដឹកនាំទីពីរ បន្ទាប់ពី ប៉ុល ពត")។

[49] "គោលបំណងនៃការជំនុំជម្រះរឿងក្តី គឺដើម្បីស្វែងរកយុត្តិធម៌ ប្រកាសសាលក្រម និង ដាក់ទណ្ឌកម្ម មិនមានអ្វីទៀតទេ ទោះបីជាអភិចរិយាបទរបស់គោលបំណងដ៏លាក់កំបាំង [...] អាចធ្វើឲ្យអន់ថយនូវបទប្បញ្ញត្តច្បាប់ដើម្បីថ្លឹងថ្លែងបទចោទប្រកាន់ប្រឆាំងជនជាប់ចោទ" Hannah Arendt, រឿងក្តី Eichmann in Jerusalem. របាយការណ៍ស្តីពី Banality of Evil, Epilogue (Penguin Book 1963).

**មេធាវីរបស់លោក អៀង សារី:**

លោក អាំង ឧត្តម　　　　ណោក Michael KARNAVAS

**មេធាវីរបស់អ្នកស្រី អៀង ធីរិទ្ធ:**

លោក ផាត់ ពៅស៊ាង　　　　កញ្ញា Diana ELLIS QC (ទីប្រឹក្សាច្បាប់)

**មេធាវីរបស់លោក ខៀវ សំផន**

លោក សាយ បូរី　　　　ណោក Jacques VERÈS